ភ្នំពេញ ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# ពិធីប្រគល់អាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដារជាលើកដំបូង



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០នាទី ព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំពិធីប្រគល់អាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី តំណាងបណ្តាសមាគមធុរកិច្ចនានា ជាពិសេសតំណាងសហគ្រាសចំនួន ៤៣ ដែលនឹងត្រូវទទួលបានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល បានសម្តែង កិច្ច-ស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានរបស់អ្នកចូលរួមទាំងអស់ ដែលបានចំណាយពេលវេលា មកចូលរួមក្នុងពិធីនេះ ព្រមទាំងសម្តែងការកោតសរសើរ ចំពោះសហគ្រាសភ្នាក់ងារសេវាកម្មពន្ធដារ ដែលនឹងត្រូវទទួលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារជាលើកដំបូង ដែលបានយកចិត្តទុកដាក់ គោរពប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ស្របតាមប្រកាស ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ និងសេចក្តីជូនដំណឹងស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានគូសបញ្ជាក់ថា ជាទិដ្ឋភាពជារួម ពិធីចែកអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារនាឱកាសនេះ គឺជាសក្ខីកម្មដ៏ថ្មីស្រឡាងមួយផ្សេងទៀត ដែល

ឆ្លុះបញ្ចាំង ពីលទ្ធផលនៃការកែទម្រង់ប្រព័ន្ធពន្ធដារកម្ពុជា ក្នុងគោលដៅបង្កើនស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ក៏ដូចជាឆ្លើយតបឲ្យបានកាន់តែប្រសើរឡើងថែមទៀតទៅនឹងតម្រូវការចាំបាច់នានា ខាងផ្នែកសេវាកម្មពន្ធដារ ព្រមទាំងជាការចូលរួមលើកកម្ពស់វប្បធ៌មនៃការបង់ពន្ធនៅ ព្រះរាជាណាចក្រឲ្យកាន់តែទូលំទូលាយថែមទៀតផងដែរ។

ពិធីប្រគល់អាជ្ញាប័ណ្ណថ្ងៃនេះ គឺជាការបង្ហាញចំពោះសាធារណជនទូទៅ នូវឱកាសដើម្បីក្លាយជា "ភ្នាក់ងាសេវាកម្មពន្ធដារ" ដែលមានលក្ខណៈជំនាញវិជ្ជាជីវៈ មានភាពទទួលខុសត្រូវខ្ពស់ និងមានការទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ ហើយមានសិទ្ធិគ្រប់គ្រាន់ស្របតាមច្បាប់ ក្នុងការបំពេញកាតព្វកិច្ច ជាភ្នាក់ងារសេវាកម្មពន្ធដារ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសលេខ ៤៥៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ភ្នាក់ងារសេវាកម្មពន្ធដារ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សាភ្ជាប់ទំនាក់ទំនងរវាងអ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ និងជាដៃគូរសហប្រតិបត្តិការមិនអាចខ្វះបាន ក្នុងការពង្រឹង និងពង្រីកការផ្តល់សេវាពន្ធដារ ជាពិសេស ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ ជូនអ្នកជាប់ពន្ធគ្រប់មជ្ឍដ្ឋាន សំដៅធានាបាននូវការអនុវត្តច្បាប់ ក៏ដូចជាការទប់ស្កាត់សកម្មភាពគេចវេះពន្ធផ្សេងៗ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានផ្តាំផ្ញើដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ភ្នាក់ងារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

សេវាកម្មពន្ធដារ ទាំងអស់ដែលជាអ្នកផ្តល់សេវាកម្មផ្នែកពន្ធដារ ត្រូវប្រើប្រាស់ជំនាញរបស់ខ្លួនដោយឈរលើស្មារតីវិជ្ជាជីវៈ ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់គោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងចូលរួមលើកកម្ពស់នូវវប្បធ៌មបង់ពន្ធឲ្យបានកាន់តែទូលំទូលាយ ក្នុងគោលដៅចូលរួមចំណែកកែទម្រង់ប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ ឲ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរ។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានវាយតម្លៃខ្ពស់ ចំពោះភ្នាក់ងារពន្ធដារ ដែលទទួលបានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ព្រមទាំងបានផ្តល់អនុសាសន៍ណែនាំបន្ថែមដល់ភ្នាក់ងារទាំងនោះ ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ និង ក្រមសីលធម៌វិជ្ជាជីវៈឲ្យបានត្រឹមត្រូវ ព្រមទាំងពង្រឹងកិច្ចសហការល្អជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការចូលរួមផ្តល់សេវាល្អប្រសើរជូនអ្នកជាប់ពន្ធ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ